# CASTOR INTERNATIONAL

**ផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិនៃ VINCI group ការផ្តល់ជូនឆ្នាំ២០២២**

**International Group Share Ownership Plan of VINCI group 2022 Offering**

## ឯកសារបន្ថែមសំរាប់ព្រះរាជាណាចក្រកម្ពុជា

*លោកអ្នកត្រូវបានអញ្ជើញអោយធ្វើការវិនិយោគលើភាគហ៊ុនដែលមាននៅក្នុង CASTOR INTERNATIONAL ដែលជាផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) នៃ VINCI group ។ ឯកសារនេះមានចែងនូវលក្ខខណ្ឌជាក់លាក់សំរាប់ប្រទេសរបស់អ្នក និងបំពេញបន្ថែមអោយឯកសារពាក់ព័ន្ធនឹងគម្រោងលក់ភាគហ៊ុន (វិធានរបស់ផែនការនៃការកាន់កាប់ ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ International Group Share Ownership Plan នៃ VINCI group និងបទបញ្ញត្តិរបស់ Fonds commun de Placement d’Enterprise CASTOR INTERNATIONAL ដែលជាមូលនិធិរួមរបស់ភាគទុនិកជានិយោជិតដែលស្ថិតនៅក្រោមច្បាប់នៃប្រទេសបារាំង (“FCPE”)) ខិត្តប័ណ្ណព័ត៌មានសង្ខេប និងពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុន។ ឯកសារនេះក៏មានបញ្ជាក់នូវសេចក្តីសង្ខេបពីផលវិបាកផ្នែកពន្ធដារ ដែលនឹងអាចកើតមានឡើងសំរាប់ការវិនិយោគរបស់អ្នក។ សូមកត់សំគាល់ថាទាំង VINCI ទាំងនិយោជករបស់អ្នក នឹងមិនផ្តល់ដំបូន្មានផ្ទាល់ខ្លួន ឬលើបញ្ហាហិរញ្ញវត្ថុ ឬពន្ធដារដែលទាក់ទងទៅនឹងការផ្តល់ជូននេះ ដល់អ្នកឡើយ។*

*វាក្យស័ព្ទមួយចំនួនដែលមិនបានអោយនិយមន័យនៅក្នុងឯកសារនេះ ត្រូវមាននិយមន័យដូចគ្នានឹងនិយមន័យដែលបានបញ្ជាក់នៅក្នុងវិធានរបស់ផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) នៃ VINCI group ។*

*សូមអានព័ត៌មានខាងក្រោមដោយប្រុងប្រយ័ត្នមុននឹងធ្វើការសំរេចចិត្តលើការវិនិយោគរបស់អ្នក៖*

### ការជូនដំណឹង ពាក់ព័ន្ធនឹងមូលប័ត្រ

លោកអ្នកត្រូវបានណែនាំអោយមានការប្រុងប្រយ័ត្នទាក់ទងនឹងការផ្តល់ជូននេះ។ ប្រសិនបើលោកអ្នកមានមន្ទិលសង្ស័យលើខ្លឹមសារនៃឯកសារនេះ លោកអ្នកគួរតែស្វែងរកនូវការប្រឹក្សាពីអ្នកជំនាញឯករាជ្យ។

តាមការយល់ដឹងរបស់ VINCI នៅកាលបរិច្ឆេទនៃការចែកចាយឯកសារនេះ ពុំមានច្បាប់ជាក់លាក់ណាមួយនៅប្រទេសកម្ពុជាដែលគ្រប់គ្រងលើការផ្តល់ជូន ឬចែកជូននូវឯកសារនេះ(តាមរយៈប្រព័ន្ធអនឡាញ) នោះទេ។ ហេតុដូច្នេះ ទាំងឯកសារនេះ ឬឯកសារណាមួយដែលបានចែកជូនលោកអ្នកនៅក្នុងបរិបទនៃការផ្តល់ជូននេះ មិនត្រូវបានទទួលការអនុម័តដោយ និយ័តករមូលបត្រកម្ពុជាទេ ពីមុនត្រូវបានគេស្គាល់ថាជាគណៈកម្មការមូលបត្រកម្ពុជា។ ឯកសារនេះ ត្រូវបានចែកជូនទៅអោយនិយោជិតដែលមានលក្ខខណ្ឌគ្រប់គ្រាន់របស់ VINCI តែប៉ុណ្ណោះ។

យ៉ាងណាមិញ ក្នុងករណីច្បាប់ ឬ តម្រូវការតាមបទប្បញ្ញត្តិពាក់ព័ន្ធនៅព្រះរាជាណាចក្រកម្ពុជាមានការកែប្រែ VINCI សូមរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការផ្តល់ជូននេះអោយអនុលោមទៅតាមអ្វីដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាតម្រូវ។ តាមរយៈការចុះឈ្មោះទិញសំរាប់ការផ្តល់ជូននេះ លោកអ្នកយល់ព្រមគោរពតាមការកែប្រែទាំងអស់នេះ និង/ឬ កាតព្វកិច្ចបន្ថែមតាមផ្លូវច្បាប់ដែលតម្រូវដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តការផ្តល់ជូននេះឱ្យមានសុពលភាព និងប្រសិទ្ធភាពក្នុងព្រះរាជាណាចក្រកម្ពុជា។

ឯកសារនេះត្រូវបានចែកជូនក្រោមលក្ខខណ្ឌនៃគោលការណ៍រក្សាការសម្ងាត់។ សិទ្ធិក្នុងការចូលរួមក្នុងការផ្តល់ជូននេះនឹងមិនត្រូវបានផ្តល់អោយដល់បុគ្គលណាម្នាក់ឡើយ ក្រៅពីបុគ្គលដែលឯកសារនេះត្រូវបានផ្ញើរទៅអោយ។ ជាពិសេស ការផ្តល់ជូននេះត្រូវធ្វើឡើងសំរាប់តែនិយោជិតរបស់ VINCI group ដែលមានសិទ្ធិទទួលបានក្នុងសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគាត់តែប៉ុណ្ណោះ។ គ្មានបុគ្គលណាម្នាក់នៅក្នុងប្រទេសកម្ពុជា អាចចាត់ទុកឯកសារនេះជាការអញ្ជើញពួកគេអោយចូលរួមក្នុងការផ្តល់ជូននេះបានឡើយ លើកលែងតែនិយោជិតដែលមានលក្ខខណ្ឌគ្រប់គ្រាន់របស់ VINCI group ដែលឯកសារនេះបានផ្ញើរទៅអោយពួកគេតែប៉ុណ្ណោះ។

ឯកសារនេះមិនត្រូវបានធ្វើសារជាថ្មី ទោះក្នុងទំរង់បែបណាក៏ដោយ ឬផ្ទេរទៅអោយបុគ្គលណាមួយក្រៅពីបុគ្គលដែលឯកសារនេះត្រូវផ្ញើរទៅអោយនោះឡើយ។

## ការគ្រប់គ្រងការប្តូរប្រាក់

នៅព្រះរាជាណាចក្រកម្ពុជា មិនមាននូវការរិតត្បិតណាមួយចំពោះប្រតិបត្តិការប្តូរប្រាក់បរទេសឡើយ លើកលែងតែក្នុងករណីកើតមានវិបត្តិនៃការប្តូរប្រាក់បរទេស (ដែលពុំមាននិយមន័យ) ដរាបណាប្រតិបត្តិការប្តូរប្រាក់បរទេសទាំងនេះត្រូវធ្វើឡើងតាមរយៈអន្តរការីដែលទទួលបានការអនុញ្ញាត ដូចជា ធនាគារដែលទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ករណីនៃការលោះមកវិញមុនពេលកំណត់

ការវិនិយោគរបស់លោកអ្នកក្នុងការផ្តល់ជូននេះត្រូវបានកាន់កាប់ (ឬ «បង្កក») ក្នុងរយៈពេល បី (៣) ឆ្នាំ លើកលែងតែក្នុងករណីមួយចំនួន ដែលលោកអ្នកត្រូវបានអនុញ្ញាតអោយលោះយកមកវិញមុនកាលកំណត់នូវឯកតារបស់ FCPE ដែលស្របតាមផែនការលក់ភាគហ៊ុន ដែលករណីទាំងនេះមាន ដូចខាងក្រោម៖

(i) ភាពអសមត្ថភាពរបស់អ្នក

(ii) មរណភាពរបស់អ្នក

(iii) ការបញ្ចប់កិច្ចសន្យាការងាររបស់អ្នក ឬ

(iv) និយោជករបស់លោកអ្នកឈប់ជាសមាជិករបស់ VINCI group (ក្រុមហ៊ុនដែលចូលរួម) ជាលទ្ធផលនៃការកាត់បន្ថយកម្រិតនៃការកាន់កាប់ ឬការគ្រប់គ្រងរបស់ VINCI ។

ករណីនៃការលោះមុនការកំណត់នេះ ត្រូវបានកំណត់ដោយផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) នៃ VINCI group ដោយយោងទៅលើច្បាប់របស់ប្រទេសបារាំង ហើយត្រូវបានបកស្រាយ និងអនុវត្តដោយអនុលោមតាមច្បាប់នេះ។ លោកអ្នកមិនត្រូវធ្វើការសន្និដ្ឋានថា ករណីនៃការលោះមុនការកំណត់នេះអាចអនុវត្តបាននោះទេ លុះត្រាតែលោកអ្នកបានរៀបរាប់អំពីករណីពិសេសរបស់លោកអ្នកទៅកាន់និយោជករបស់លោកអ្នក ហើយនិយោជកបានបញ្ជាក់ជាលាយលក្ខណ៍អក្សរថា ករណីនេះត្រូវយកមកអនុវត្តចំពោះស្ថានភាពរបស់លោកអ្នក ដោយយោងតាមឯកសារគាំទ្រដែលតម្រូវអោយលោកអ្នកផ្តល់ទៅអោយនិយោជក។

ក្នុងករណីនៃការលោះយកវិញមុនកាលកំណត់នូវឯកតារបស់លោកអ្នកនៅក្នុង FCPE លោកអ្នកនឹងលែងមានសិទ្ធិទទួលបានភាគហ៊ុនបន្ថែម (“Bonus Shares”) ទៀតហើយ។ សូមកត់សំគាល់ថា ក្នុងករណីខ្លះដូចដែលបានបញ្ជាក់នៅក្នុងផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) នៃ VINCI group និងដែលបានបញ្ជាក់ដោយសង្ខេបនៅក្នុងខិត្តប័ណ្ណពត៌មានសង្ខេប និងដោយមិនយោងតាមការស្នើសុំលោះយកមកវិញមុនកាលកំណត់ លោកអ្នកអាចមានសិទ្ធិទទួលការទូទាត់សំណងជាសាច់ប្រាក់ជំនួសអោយភាគហ៊ុនបន្ថែម (“Bonus Shares”)។

## ដំណើរការនៃការចុះឈ្មោះទិញ

លោកអ្នកអាចចូលរួមដាក់ពាក្យស្នើសុំចុះឈ្មោះទិញរបស់លោកអ្នកលើគេហទំព័រ castor.vinci.com ដោយប្រើ user ID និងលេខសំងាត់សំរាប់ចូលដែលផ្តល់ជូនលោកអ្នកដាច់ដោយឡែក។

## ព័ត៌មានអំពីពន្ធ

*សេចក្តីសង្ខេបខាងក្រោមនេះ រៀបរាប់អំពីគោលការណ៍ទូទៅដែលត្រូវបានរំពឹងថានឹងអនុវត្តទៅលើនិយោជិតដែលជានិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា សំរាប់គោលបំណងអនុវត្តច្បាប់សារពើពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា។ លទ្ធផលពន្ធដែលរៀបរាប់ខាងក្រោម គឺធ្វើឡើងស្របទៅតាមច្បាប់ពន្ធដារ ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន ព្រមទាំងច្បាប់ពន្ធដារ និងការអនុវត្តមួយចំនួននៃប្រទេសបារាំង។ គោលការណ៍ និងច្បាប់ទាំងនេះអាចមានការផ្លាស់ប្តូរគ្រប់ពេលវេលា។ និយោជិតគួរតែពិចារណាលើស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ។*

*សម្រាប់ដំបូន្មានជាក់លាក់ និយោជិតគួរតែពិគ្រោះជាមួយនឹងទីប្រឹក្សាពន្ធដាររបស់ខ្លួនផ្ទាល់ទាក់ទងនឹងលទ្ធផលពន្ធដារនៃការទិញភាគហ៊ុនរបស់ក្រុមហ៊ុន VINCI។ សេចក្តីសង្ខេបនេះត្រូវបានផ្តល់សម្រាប់គោលបំណងព័ត៌មានតែប៉ុណ្ណោះ និងមិនគួរត្រូវបានយកមកធ្វើជាមូលដ្ឋានពឹងផ្អែកទាំងស្រុង ឬសម្រាប់ធ្វើសេចក្តីសន្និដ្ឋានឡើយ។*

## I. ភាគព្វកិច្ចពន្ធដារទាក់ទងនឹងការចុះឈ្មោះទិញភាគហ៊ុនតាមរយៈ FCPE៖

ភាគហ៊ុនដែលត្រូវបានចុះឈ្មោះទិញដោយប្រើប្រាស់នូវវិភាគទានផ្ទាល់ខ្លួនរបស់លោកអ្នក នឹងត្រូវរក្សាទុក ដោយ *Fonds Commun de Placement d'Entreprise* CASTOR INTERNATIONAL ដែលជាមូលនិធិកាន់កាប់ភាគហ៊ុនរបស់និយោជិតជារួម ដែលបង្កើតឡើងតាមច្បាប់របស់ប្រទេសបារាំង។ ការវិនិយោគរបស់លោកអ្នកនឹងត្រូវបានបង្ហាញជាភស្តុតាងតាមរយៈឯកតានៅក្នុង FCPE ដែលអ្នកនឹងកាន់កាប់។ ការចុះឈ្មោះទិញភាគហ៊ុននឹងធ្វើឡើងតាមរយៈ FCPE CASTOR INTERNATIONAL RELAIS 2022 ដែលនឹងត្រូវបញ្ចូលគ្នាទៅក្នុង FCPE។

### A. សារពើពន្ធនៅប្រទេសបារាំង

អ្នកមិនត្រូវជាប់ពន្ធ ឬបន្ទុករបបសង្គមនៅក្នុងប្រទេសបារាំងនៅពេលដែលចុះឈ្មោះទិញ ឬក៏លោះយកមកវិញនូវឯកតា FCPE របស់អ្នកទេ។ ប្រសិនបើការវិនិយោគរបស់អ្នកធ្វើឡើងតាមរយៈ FCPE អ្នកមិនត្រូវជាប់ពន្ធ ឬបន្ទុករបបសង្គមនៅក្នុងប្រទេសបារាំង ចំពោះភាគលាភដែលផ្តល់ដោយ VINCI និងការវិនិយោគឡើងវិញដោយ FCPE ឡើយ។

### B. សារពើពន្ធនៅព្រះរាជាណាចក្រកម្ពុជា

***ពន្ធ និង/ឬ បន្ទុករបបសន្តិសុខសង្គមដែលអាចត្រូវអនុវត្តនៅពេលចុះឈ្មោះទិញភាគហ៊ុន***

សូមកត់សម្គាល់ថា គ្មានការបញ្ចុះតម្លៃលើតម្លៃទីផ្សារនៃភាគហ៊ុន ត្រូវបានផ្តល់ជូននៅពេលមានការចុះឈ្មោះទិញភាគហ៊ុនរបស់អ្នក។ ដូចនេះ អ្នកមិនត្រូវជាប់ពន្ធ ឬបន្ទុករបបសន្តិសុខសង្គមទេនៅពេលចុះឈ្មោះទិញ។

***ពន្ធ និង/ឬ បន្ទុករបបសន្តិសុខសង្គមដែលអាចត្រូវអនុវត្តទៅលើភាគលាភដែលទទួលដោយ FCPE***

អ្នកមិនត្រូវជាប់ពន្ធ ឬបន្ទុករបបសន្តិសុខសង្គមទៅលើភាគលាភដែលវិនិយោគឡើងវិញនៅក្នុង FCPE។

***ពន្ធ និង/ឬ បន្ទុករបបសន្តិសុខសង្គមដែលអាចត្រូវអនុវត្តទៅលើការលោះយកមកវិញនូវឯកតារបស់លោកអ្នកនៅក្នុង FCPE***

អ្នកមិនត្រូវជាប់ពន្ធ លើការលោះយកមកវិញនូវឯកតា FCPE ទេ។ យ៉ាងណាមិញ អ្នកអាចត្រូវជាប់ពន្ធលើប្រាក់ចំណូលសម្រាប់រូបវន្តបុគ្គល នៅពេលដែលយន្តការសម្រាប់ពន្ធលើប្រាក់ចំណូលសម្រាប់រូបវន្តបុគ្គលដែលបានប្រមូលត្រូវបានបង្កើតឡើង។ ពុំមានជាប់បន្ទុករបបសន្តិសុខសង្គមឡើយ។

## II. ពន្ធដែលអាចត្រូវអនុវត្តនៅលើភាគហ៊ុនបន្ថែម ("Bonus Shares") ផ្តល់ដោយ VINCI

បន្ថែមលើតម្លៃចុះឈ្មោះទិញ អ្នកគួរតែត្រូវបានផ្តល់ដោយ VINCI នូវសិទ្ធិក្នុងការទទួលបានភាគហ៊ុនពី VINCI ដោយឥតគិតថ្លៃ ("ភាគហ៊ុនបន្ថែម" ("Bonus Shares")) ក្នុងការដែលបំពេញនូវលក្ខខណ្ឌជាក់លាក់មួយចំនួនដែល រៀបរាប់នៅក្នុងផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Employee Shareholding Plan) និងខិត្តប័ណ្ណព័ត៌មានសង្ខេប

(Information Brochure)។ ដរាបណាបានបំពេញលក្ខខណ្ឌទាំងអស់ ភាគហ៊ុនទាំងអស់នេះនឹងត្រូវបានបញ្ជូនទៅក្នុង FCPE នៅចុងដំណាក់កាលផ្ទេរនៅក្នុងឆ្នាំ២០២៥។ យ៉ាងណាមិញ អ្នកក៏នឹងមានលទ្ធភាពក្នុងការកាន់ភាគហ៊ុននៅក្នុងគណនីភាគហ៊ុនដែលមានឈ្មោះរបស់អ្នក។ ក្នុងករណីជាក់លាក់មួយចំនួន អ្នកអាចទទួលបាននូវការទូទាត់សំណងជាសាច់ប្រាក់ពីនិយោជករបស់អ្នកជំនួសការផ្តល់ភាគហ៊ុនបន្ថែម ("Bonus Shares") ដូចដែលមានចែងក្នុងផែនការនៃការកាន់កាប់ភាគហ៊ុនរបស់និយោជិកជាអន្តរជាតិ (International Employee Shareholding Plan) និង ខិត្តប័ណ្ណព័ត៌មានសង្ខេប (Information Brochure)។

### A. ពន្ធនៅប្រទេសបារាំង

អ្នកមិនត្រូវជាប់ពន្ធ ឬបន្ទុករបបសន្តិសុខសង្គមនៅក្នុងប្រទេសបារាំងទេ ទៅលើការផ្តល់ការបញ្ជូនឬការលក់នូវភាគហ៊ុនរបស់ VINCI ដែលបានមកដោយឥតគិតថ្លៃ។ បន្ទុកពន្ធទៅលើភាគលាភដែលទទួលបានពីភាគហ៊ុនរបស់ VINCI បន្ទាប់ពីការផ្តល់អោយគឺអាស្រ័យលើការសម្រេចចិត្តរបស់លោកអ្នក ថាតើត្រូវរក្សាទុកភាគហ៊ុនបន្ថែម ("Bonus Shares") នៅក្នុង FCPE ឬកាន់កាប់ដោយផ្ទាល់ (សូមពិនិត្យខាងក្រោម)។

### B. ពន្ធនៅព្រះរាជាណាចក្រកម្ពុជា

***ពន្ធ និង/ឬ បន្ទុករបបសន្តិសុខសង្គមដែលអាចត្រូវអនុវត្តទៅលើការផ្តល់សិទ្ធិទទួលបានភាគហ៊ុនបន្ថែម ("Bonus Shares") ដោយ VINCI***

គ្មានពន្ធ និង/ឬ បន្ទុករបបសន្តិសុខសង្គមដែលអាចត្រូវអនុវត្តនៅពេលផ្តល់សិទ្ធិទទួលបានភាគហ៊ុនបន្ថែម ("Bonus Shares") ដោយ VINCI ទេ។

***ពន្ធ និង/ឬ បន្ទុករបបសន្តិសុខសង្គមដែលអាចត្រូវអនុវត្តនៅពេលភាគហ៊ុនបន្ថែម*** *("Bonus Shares")* ***ត្រូវបានផ្ទេរ***

នៅពេលដែលភាគហ៊ុនបន្ថែមត្រូវបានផ្ទេរនៅក្នុង FCPE នោះលោកអ្នកនឹងត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលគណនានៅលើតម្លៃជាប់ពន្ធដែលស្មើនឹងតម្លៃទីផ្សាររបស់ភាគហ៊ុន VINCI នៅថ្ងៃចែកចាយ។

ដើម្បីគោលបំណងគណនាបំណុលពន្ធលើអត្ថប្រយោជន៍បន្ថែម នៅក្នុងខែដែលភាគហ៊ុនបន្ថែមត្រូវបានផ្ទេរ តម្លៃទីផ្សាររបស់ភាគហ៊ុន VINCI នឹងត្រូវបានចាត់ទុកថាជាអត្ថប្រយោជន៍បន្ថែមក្រោមច្បាប់ពន្ធដារកម្ពុជា។ អត្ថប្រយោជន៍បន្ថែមនេះ នឹងត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមនៅអត្រា 20%។ ពន្ធលើអត្ថប្រយោជន៍បន្ថែម នឹងត្រូវបានកាត់ទុកដោយនិយោជករបស់លោកអ្នក។

សូមកត់សម្គាល់ផងដែរថា ធាតុជាសាច់ប្រាក់សុទ្ធនៃប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមរបស់អ្នក ប្រហែលជាមិនគ្រប់គ្រាន់ ក្នុងការបង់ពន្ធលើប្រាក់បៀវត្សនោះទេ។ យ៉ាងណាមិញ ចំណែកខ្លះនៃភាគហ៊ុនបន្ថែមរបស់លោកអ្នកអាចនឹងត្រូវបានលក់នៅពេលផ្ទេរ ដើម្បីបង់បន្ទុកពន្ធ។

បន្ទុករបបសន្តិសុខសង្គមមិនត្រូវបានអនុវត្តទេ។

បន្ទុកសារពើពន្ធដូចគ្នា នឹងត្រូវអនុវត្តប្រសិនបើលោកអ្នកសំរេចចិត្តថាកាន់កាប់ភាគហ៊ុនបន្ថែមរបស់អ្នកដោយផ្ទាល់។ គ្មានបន្ទុកសារពើពន្ធបន្ថែមណាមួយនឹងត្រូវអនុវត្តឡើយ ប្រសិនបើលោកអ្នកលក់ភាគហ៊ុនបន្ថែមរបស់លោកអ្នកនៅពេលផ្ទេរ។

*ពន្ធ និង/ឬ បន្ទុករបបសន្តិសុខសង្គមដែលអាចត្រូវអនុវត្តទៅលើភាគលាភដែលអាចនឹងចែកដល់លោកអ្នកបន្ទាប់ពីការផ្ទេរនូវភាគហ៊ុនបន្ថែម*

ប្រសិនបើលោកអ្នកសំរេចចិត្តថារក្សាទុកភាគហ៊ុនបន្ថែមរបស់លោកអ្នកនៅក្នុង FCPE ភាគលាភនឹងត្រូវបានយកទៅវិនិយោគឡើងវិញនៅក្នុង FCPE។ លោកអ្នកមិនគួរជាប់ពន្ធបន្ថែមចំពោះការវិនិយោគឡើងវិញនេះទេ។

ប្រសិនបើអ្នកសំរេចចិត្តថាកាន់កាប់ភាគហ៊ុនបន្ថែមរបស់អ្នកដោយផ្ទាល់ ភាគលាភ (ប្រសិនបើមាន) នឹងត្រូវជាប់ពន្ធកាត់ទុកនៅក្នុងប្រទេសបារាំង ក្នុងអត្រា ១២,៨០%[1]។ គ្មានពន្ធបន្ថែមទៀតដែលត្រូវបានអនុវត្តលើភាគលាភទាំងនោះសម្រាប់និវេសនជនក្នុងព្រះរាជាណាចក្រកម្ពុជាទេ។

ពុំមានជាប់បន្ទុករបបសន្តិសុខសង្គមឡើយ។

***ពន្ធ និង/ឬ បន្ទុករបបសន្តិសុខសង្គមដែលអាចត្រូវអនុវត្តនៅពេលដែលឯកតា FCPE ត្រូវលោះមកវិញ***

អ្នកមិនគួរជាប់ពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ នៅពេលដែលឯកតា FCPE របស់លោកអ្នកត្រូវលោះមកវិញ។ យ៉ាងណាមិញ អ្នកអាចត្រូវមានចំណូលជាប់កាតព្វកិច្ចពន្ធសម្រាប់រូបវន្តបុគ្គល នៅពេលដែល យន្តការសម្រាប់ចំណូលដែលជាប់កាតព្វកិច្ចរបស់រូបវន្តបុគ្គលដែលបានប្រមូលត្រូវបានបង្កើតឡើង។

បន្ទុករបបសន្តិសុខសង្គមមិនត្រូវអនុវត្តទេ។

*ពន្ធ និង/ឬ បន្ទុករបបសន្តិសុខសង្គមដែលអាចត្រូវអនុវត្តនៅពេលសំណងជាសាច់ប្រាក់ត្រូវបានបង់ (ប្រសិនបើមាន) ដោយនិយោជក ជំនួសការផ្ទេរភាគហ៊ុនបន្ថែម*

---

[1] អត្រាកើនឡើងដល់ ៧៥% ប្រសិនបើភាគលាភត្រូវបានទូទាត់ចូលក្នុងគណនីធនាគារមួយដែលបើកនៅរដ្ឋ ឬតំបន់ដែលមិនមានកិច្ចសហការ (Non Cooperative State or Territory "NCST") លុះត្រាតែការទូទាត់ភាគលាភនៅក្នុង NCST មិនមានវត្ថុ ឬ ឥទ្ធពលនៃការកំណត់ទីតាំងភាគលាភនៅក្នុង NCST បែបនេះសម្រាប់គោលបំណងគេចពន្ធ។ នៅពេលរៀបចំឯកសារនេះ បញ្ជីឈ្មោះរដ្ឋ និងតំបន់ដែលបំពេញលក្ខខណ្ឌជា NCST រួម Anguilla, Dominica, Fiji, Guam, United States Virgin Islands, British Virgin Islands, Palau, Panama, American Samoa, Samoa, Seychelles, Trinidad and Tobago and Vanuatu។

ប្រសិនបើលោកអ្នកមានសិទ្ធិក្នុងការទទួលបានការទូទាត់សំណងជាសាច់ប្រាក់ ជំនួសការផ្ទេរភាគហ៊ុនបន្ថែម ទឹកប្រាក់សំណងជាសាច់ប្រាក់នោះនឹងត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អត្រាពន្ធដែលអនុវត្តគឺចាប់ពី ២០%។ ពន្ធលើអត្ថប្រយោជន៍បន្ថែមនឹងត្រូវបានកាត់ទុកដោយនិយោជករបស់អ្នក។

បន្ទុករបបសន្តិសុខសង្គមមិនត្រូវអនុវត្តទេ។